គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច

# គោលការណ៍ណែនាំស្តីពីមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ

(Sector Development Facilities)

កំណែទី១ ឆ្នាំ ២០១៨

# មាតិកា


១. សេចក្តីផ្តើម ........ 2

១.១. តើគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូចគឺជាអ្វី? ........ 2

១.២. គោលការណ៍ណែនាំស្តីពីមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ ........ 2

២. មូលនិធិសម្របសម្រួលការអភិវឌ្ឍតាមវិស័យ ........ 3

២.១. គោលការណ៍ទូទៅ ........ 3

២.២. ការគ្រប់គ្រងមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ ........ 4

២.៣. ការកំណត់សញ្ញាណវិនិយោគក្រោមមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ ........ 4

២.៤. ការអនុម័តលើការវិនិយោគមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ ........ 5

២.៥. ការដាក់សំណើសុំថវិកា ........ 6

២.៦. ការវាយតម្លៃលើសំណើ ........ 7

២.៧. ការផ្តល់មូលនិធិ ........ 8

៣. ការគ្រប់គ្រងវិនិយោគមូលនិធិសម្របសម្រួលការអភិវឌ្ឍតាមវិស័យ ........ 9

៣.១. ជំនួយផ្នែកបច្ចេកទេសសម្រាប់ការបង្កើត និងអនុវត្តសំណើ ........ 9

៣.២. លទ្ធកម្ម ........ 9

៣.៤. ការរៀបចំចាត់ចែងជួសជុល និងថែទាំ ........ 9

# ១. សេចក្តីផ្តើម

## ១.១. តើគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូចគឺជាអ្វី?

១. គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (AIMS) គឺជាគម្រោងរួមគ្នារបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD)។ ដូចនឹងឈ្មោះដែលផ្តល់ឲ្យ គម្រោងនេះមានគោលបំណងជំរុញកំណើនទីផ្សារ និងសម្រាប់ផលិតផលកសិកម្មដែលមានតម្លៃខ្ពស់ និងការអភិវឌ្ឍចង្កោមផលិតផលតាមមូលដ្ឋាន ដែលក្រុមកសិករខ្នាតតូចក្រីក្រជាអ្នកផលិតអាចទទួលបានផលប្រយោជន៍រួមគ្នា។

២. គម្រោងមានរយៈពេលប្រាំមួយឆ្នាំ គិតចាប់ពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ហើយអាចបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

៣. គម្រោងត្រូវអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជាជាមួយដៃគូអនុវត្តន៍ផ្សេងៗ ហើយត្រូវបានរំពឹងថានឹងមានមូលនិធិរួមបញ្ចូលគ្នាសរុបពីរាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្មក្នុងតម្លៃប្រមាណជា ៤៥ លានដុល្លារអាមេរិក។

## ១.២. គោលការណ៍ណែនាំស្តីពីមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ

៤. គោលការណ៍ណែនាំស្តីពីមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ (SDF) ត្រូវបានបង្កើតឡើងជាសៀវភៅណែនាំសម្រាប់ធ្វើការវិនិយោគសាធារណៈ ដោយក្នុងនោះកំណត់អំពីវិធីសាស្រ្តសម្រាប់ជ្រើសរើស អនុវត្ត និងគ្រប់គ្រងរដ្ឋបាល។ ឯកសារនេះរួមមានសេចក្តីសង្ខេបអំពីមូលនិធិសម្របសម្រួលការអភិវឌ្ឍតាមវិស័យ និងវិធីប្រតិបត្តិដែលត្រូវអនុវត្តនៅក្នុងគម្រោង។ ព័ត៌មានលំអិតអំពីការវិភាគពេញលេញលើបរិបទ ហេតុផល វិធីសាស្រ្តនៃគម្រោង និងមូលនិធិនេះផ្ទាល់គឺមានចែងក្នុងរបាយការណ៍រៀបចំគម្រោង (Project Design Report) ដែលជាឯកសារយោង។

៥. គោលការណ៍ណែនាំនេះ មានគោលបំណងពិសេសដើម្បីផ្តល់ការណែនាំដល់ក្រុមអនុវត្តគម្រោង នាយកគម្រោង និងគណៈកម្មការត្រួតពិនិត្យលទ្ធកម្ម[1] ក្នុងការធ្វើសេចក្តីសម្រេចលើការប្រើប្រាស់មូលនិធិនេះ។

៦. គោលការណ៍ណែនាំនេះនឹងកំណត់ពីគោលការណ៍អភិបាលកិច្ចលើការគ្រប់គ្រងមូលនិធិ នីតិវិធី និងលក្ខណវិនិច្ឆ័យដែលត្រូវប្រើសម្រាប់ជ្រើសរើស និងដំណើរការអនុម័តលើការវិនិយោគក្រោមមូលនិធិនេះ។ គោលការណ៍នេះផ្តល់នូវឧបករណ៍សម្រាប់គ្រប់គ្រង និងចាត់ចែងអនុគម្រោងដើម្បីធានាបានថា

[1] សម្រាប់ប្រើប្រាស់នៅក្នុងគោលការណ៍ណែនាំនេះតែប៉ុណ្ណោះ គណៈកម្មការត្រួតពិនិត្យលទ្ធកម្មក្នុងន័យនេះ គឺមានតែសមាជិកមកពីក្រសួងពាណិជ្ជកម្មតែប៉ុណ្ណោះ និងត្រូវប្រើប្រាស់នីតិវិធីមានចែងក្នុងគោលការណ៍ណែនាំនេះ

ការវិនិយោគទាំងឡាយក្រោមមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យត្រូវបានអនុវត្តដោយអនុលោមទៅតាមគោលបំណងរបស់មូលនិធីនេះពិតប្រាកដ។

៧. គោលការណ៍ណែនាំស្តីពីមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ ជាផ្នែកមួយបន្ថែមទៅលើសៀវភៅណែនាំអនុវត្តគម្រោង (Project Implementation Manual) និងរបាយការណ៍រៀបចំគម្រោង (Project Design Report)។

# ២. មូលនិធិសម្របសម្រួលការអភិវឌ្ឍតាមវិស័យ

## ២.១. គោលការណ៍ទូទៅ

៨. មូលនិធិសម្របសម្រួលការអភិវឌ្ឍតាមវិស័យ គឺជាមូលនិធិឥតសំណងនៅក្នុងសមាសភាគទី ១ ស្តីពីការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ។ មូលនិធិនេះផ្តោតលើការវិនិយោគជា "ទ្រព្យសម្បត្តិសាធារណៈ" ដើម្បីដោះស្រាយបញ្ហាជាក់លាក់ណាមួយដែលរាំងស្ទះដល់ការអភិវឌ្ឍខ្សែសង្វាក់តម្លៃ ដែលកំណត់ដោយតួអង្គខ្សែសង្វាក់តម្លៃដោយខ្លួនឯង តាមរយៈដំណើរការកិច្ចសន្ទនានៃវេទិកាសម្របសម្រួលពហុភាគីពាក់ព័ន្ធ (Multi-Stakeholder Platform (MSP))។ មូលនិធិនេះនឹងផ្តោតលើការវិនិយោគសាធារណៈតែប៉ុណ្ណោះ ដោយយល់ថាក្នុងបរិបទបច្ចុប្បន្នរបស់ខ្សែសង្វាក់តម្លៃគោលដៅ មិនមានចំណាប់អារម្មណ៍ពីភាគីឯកជន ឬអាចទាក់ទាញការវិនិយោគឯកជននៅឡើយ។

៩. ជាលក្ខខណ្ឌមួយសម្រាប់មូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ ដៃគូអនុវត្តក្នុងមូលនិធិនេះនឹងត្រូវផ្តល់វិភាគទានហិរញ្ញវត្ថុយ៉ាងហោចណាស់ ៥% (ឬប្រហាក់ប្រហែល (in-kind)) ដល់ការវិនិយោគទាំងអស់ ដើម្បីបញ្ជាក់ថាពួកគេមានចំណាប់អារម្មណ៍ជាអាទិភាព និងការវិនិយោគនេះជាតម្រូវការបន្ទាន់សម្រាប់អនុវត្តខ្សែសង្វាក់តម្លៃគោលដៅ។

១០. ប្រភេទវិនិយោគដែលរំពឹងទុកនៅក្រោមមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ រួមបញ្ចូលទាំងការវិនិយោគក្នុងទីផ្សាររូបវន្ត ចំនុចប្រមូលផ្តុំ ប្រព័ន្ធព័ត៌មានវិទ្យាទីផ្សារ ការធ្វើឱ្យប្រសើរឡើងនូវមន្ទីរពិសោធន៍សាកល្បងសាធារណៈ ឬពង្រឹងសមត្ថភាពអធិការកិច្ចលើអនាម័យនិងភូតគាមអនាម័យ (SPS) ការពង្រឹងសមត្ថភាពស្រាវជ្រាវខាងពាណិជ្ជកម្ម ការគាំទ្រដល់ការចរចាអនាម័យ និងភូតគាមអនាម័យទ្វេភាគី ការសាកល្បងគំរូអាជីវកម្មថ្មី ឬដែលមិនទាន់មានការសាកល្បង (ឧ. សម្រាប់ថ្នាលបណ្តុះដំឡូងមីដែលមានសុខភាព) ការបង្ហាញ និងការផ្សព្វផ្សាយលើបច្ចេកវិទ្យាថ្មីៗ ឬប្រព័ន្ធផលិតកម្ម ការស្រាវជ្រាវសកម្មភាព ការសិក្សាទីផ្សារ ការអភិវឌ្ឍបណ្តាញឧស្សាហកម្ម និងការកសាងសមត្ថភាពជាដើម ។ល។ សំណើទាំងឡាយត្រូវរួមបញ្ចូលការអន្តរាគមន៍ទាំងអស់ដែលចាំបាច់ទាំង "ផ្នែករឹង" ក៏ដូចជា "ផ្នែកទន់" ឧទាហរណ៍ ការពង្រីកទីផ្សារលក់ដុំត្រូវរួមបញ្ចូលទាំងការគាំទ្រដល់របៀបគ្រប់គ្រងប្រសិទ្ធភាពទីផ្សារលក់ដុំដែលមានគណៈកម្មាធិការគ្រប់គ្រង រចនាសម្ព័ន្ធតម្លៃ ការកសាងសមត្ថភាពហិរញ្ញវត្ថុ និងប្រតិបត្តិការ ។ល។

១១. មូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យក៏អាចប្រើប្រាស់បាន ដើម្បីផ្តល់ឥណទានឥតសំណងដល់សកម្មភាពភាពជាដៃគូជាមួយដៃគូយុទ្ធសាស្ត្ររបស់គម្រោងដែលមានឯកទេសជំនាញ ចំណេះដឹង ឬបណ្តាញស្រាប់ ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍គម្រោង។ ការរៀបចំ និងអនុម័តលើការផ្តល់ឥណទានឥតសំណងសម្រាប់សកម្មភាពភាពជាដៃគូត្រូវអនុវត្តតាមដំណើរការដូចគ្នានឹងជំនួយឥតសំណងដទៃទៀត ដែលស្ថិតនៅក្រោមមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យផងដែរ។

## ២.២. ការគ្រប់គ្រងមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ

១២. ការវិនិយោគដោយប្រើប្រាស់ថវិកាពីមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ អាចគ្រប់គ្រងផ្ទាល់ដោយការិយាល័យគ្រប់គ្រងគម្រោងនៃក្រសួងពាណិជ្ជកម្ម ឬដោយដៃគូអនុវត្តមូលនិធិ (SDF Partner) ដែលជាម្ចាស់សំណើសុំថវិកា ដូចជា៖ សហគមន៍កសិករ ក្រុម ឬសមាគមឯកជនប្រហាក់ប្រហែល ភ្នាក់ងារជំនាញបច្ចេកទេស ឬអង្គភាពសាធារណៈ។ ក្នុងករណីដែលការគ្រប់គ្រងលើការវិនិយោគជាភារកិច្ចរបស់ដៃគូ នោះកិច្ចសន្យាស្តីពីការទទួលមូលនិធិនឹងត្រូវបង្កើតឡើង ដោយកំណត់តួនាទី និងការទទួលខុសត្រូវរបស់ដៃគូនិមួយៗ នីតិវិធី និងបទដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ គណនេយ្យ វិធីសាស្ត្រលទ្ធកម្ម ត្រួតពិនិត្យ និងវាយតម្លៃ។ សំរាប់ការវិនិយោគដែលគ្រប់គ្រងដោយការិយាល័យគ្រប់គ្រងគម្រោងផ្ទាល់ វិធីសាស្ត្រលទ្ធកម្មសម្រាប់ទំនិញ សំណង់ស៊ីវិល និងសេវាទីប្រឹក្សាដែលប្រើថវិកាពីមូលនិធិនេះ ត្រូវគ្រប់គ្រងដោយនីតិវិធីលទ្ធកម្ម នៃនីតិវិធីរួមរបស់រាជរដ្ឋាភិបាល។

## ២.៣. ការកំណត់សញ្ញាណវិនិយោគក្រោមមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ

១៣. ការកំណត់សញ្ញាណវិនិយោគនៅក្រោមមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ ត្រូវកំណត់ដោយតួអង្គទាំងឡាយនៃខ្សែសង្វាក់តម្លៃដោយខ្លួនឯង តាមរយៈដំណើរការនៃវេទិកាសម្របសម្រួលពហុភាគីពាក់ព័ន្ធ (MSP)។ ការវិនិយោគ "ទ្រព្យសម្បត្តិសាធារណៈ" ផ្សេងទៀតក៏អាចកំណត់បានដោយមិនចាំបាច់ឆ្លងកាត់វេទិកាសម្របសម្រួលពហុភាគីពាក់ព័ន្ធ (MSP) បើសិនជាមានដំណោះស្រាយច្បាស់លាស់សម្រាប់បញ្ហាប្រឈមរាំងស្ទះនៅក្នុងខ្សែសង្វាក់តម្លៃនីមួយៗ។

១៤. វេទិកាសម្របសម្រួលពហុភាគីពាក់ព័ន្ធ (MSP) នៅក្នុងគម្រោងជំរុញទីផ្សារសម្រាប់កសិករខ្នាតតូច គឺជាយន្តការសំខាន់មួយក្នុងការងារសម្របសម្រួលដល់ការអភិវឌ្ឍខ្សែសង្វាក់តម្លៃនីមួយៗ ប្រកបដោយបរិយាប័ន្ន។ វេទិកានេះចាប់ផ្តើមពីសិក្ខាសាលាផ្តល់សុពលភាពក្រៅផ្លូវការសម្រាប់ខ្សែសង្វាក់តម្លៃនីមួយៗ ការពិភាក្សានេះនឹងធ្វើឡើងដោយមានការចូលរួមពីអ្នកទិញ ពាណិជ្ជករ អាជីវករ តំណាងក្រុមអ្នកផលិត និងអ្នកផ្តល់សេវា។

១៥. នៅពេលដែលវេទិកាសម្របសម្រួលពហុភាគីពាក់ព័ន្ធ (MSP) ត្រូវបានអនុវត្ត អ្នកពាក់ព័ន្ធសំខាន់ៗក្នុងចង្កោមនីមួយៗ ត្រូវបង្កើតផែនការសកម្មភាពរួមគ្នាមួយ ក្រោមការជួយសម្របសម្រួលដោយក្រុម

ការងារខ្សែសង្វាក់តម្លៃ។ ផែនការសកម្មភាពចាំបាច់ត្រូវផ្តោតលើឱកាសក្នុងការទាញយកផលប្រយោជន៍ពីទីផ្សារភ្លាមៗ ឬដោះស្រាយបញ្ហារាំងស្ទះក្នុងមូលដ្ឋានឱ្យបានភ្លាមៗ។ ក្រោយពីនោះមក ផែនការទាំងនេះនឹងស្របតាមចក្ខុវិស័យដែលបានព្រមព្រៀងគ្នាសម្រាប់ខ្សែសង្វាក់តម្លៃ និងឆ្ពោះទៅរកសកម្មភាពមួយដែលមានការសម្របសម្រួលពេញលេញ។ ផែនការទាំងនេះត្រូវតែផ្តោតលើឱកាស ឬដោះស្រាយឧបសគ្គជាយុទ្ធសាស្ត្របន្ថែមទៀត ដែលអាចប៉ះពាល់ដល់កំណើនរយៈពេលវែង និងភាពរស់រវើកនៃវិស័យក្នុងស្រុក ក៏ដូចជាការអភិវឌ្ឍទីផ្សារសេវាមូលដ្ឋានសំខាន់ៗ ដែលចាំបាច់សម្រាប់ការរក្សាកំណើនឱ្យមាននិរន្តរភាព។

១៦. ផែនការសកម្មភាពនឹងកំណត់ពីការគាំទ្រផ្នែកហិរញ្ញវត្ថុ ដែលអាចទទួលបានតាមរយៈ៖

(ក) សំណើសម្រាប់ទទួលយកឥណទានឥតសំណងសម្រាប់ការវិនិយោគឯកជន តាមរយៈមូលនិធិនវានុវត្តន៍ខ្សែសង្វាក់តម្លៃ (Value Chain Innovation Fund (VCIF))

(ខ) ការគាំទ្រគម្រោងដោយផ្ទាល់សម្រាប់ការវិនិយោគ "ទ្រព្យសម្បត្តិសាធារណៈ" តាមរយៈមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ (SDF) និង

(គ) តភ្ជាប់ទំនាក់ទំនងរវាងតួអង្គខ្សែសង្វាក់តម្លៃទាំងអស់ ជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុសម្រាប់ការផ្តល់ហិរញ្ញប្បទានបន្ថែមតាមរយៈប្រាក់កម្ចី។

## ២.៤. ការអនុម័តលើការវិនិយោគមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ

១៧. រាល់សំណើវិនិយោគប្រើប្រាស់មូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ ដែលត្រូវបានកំណត់ក្នុងផែនការសកម្មភាពនៃខ្សែសង្វាក់តម្លៃ ដែលបានរៀបចំតាមរយៈវេទិកាសម្របសម្រួលពហុភាគីពាក់ព័ន្ធ (MSP) ឬដោយផ្ទាល់តាមរយៈការកំណត់សញ្ញាណដោយត្រឹមត្រូវ និងឆ្លើយតបនឹងតម្រូវការជាក់ស្តែងសម្រាប់ខ្សែសង្វាក់តម្លៃ ត្រូវបង្ហាញឱ្យបានច្បាស់អំពីផលប៉ះពាល់ គោលបំណង លទ្ធផល និងនិរន្តរភាពនៃការអនុវត្ត។ សំណើវិនិយោគមូលនិធិដោយឡែកត្រូវបញ្ជូនទៅក្រុមការងារសម្រាប់ការពិចារណា។ លើសពីនេះទៀត សំណើនេះត្រូវបង្ហាញពីលទ្ធភាពក្នុងការរួមចំណែកជាវិភាគទានផ្នែកហិរញ្ញវត្ថុ (យ៉ាងហោចណាស់៥% នៃការវិនិយោគសរុប ឬមានតម្លៃស្មើ (in-kind)) ដោយតួអង្គក្នុងវិស័យឯកជន ព្រមទាំងបញ្ជាក់ថាថវិការួមចំណែកនេះនឹងត្រូវបានគ្រប់គ្រងជាផ្នែកមួយនៃអនុគម្រោងវិនិយោគ។

១៨. លក្ខណវិនិច្ឆ័យស្តីពីបរិយាប័ន្ន គួរតែមានបង្ហាញនៅក្នុងសំណើ ដោយទំហំនៃការចូលរួមដោយបរិយាប័ន្ននេះអាចក្នុងកម្រិតចង្កោម កម្រិតមណ្ឌលភូមិភាគ ឬកម្រិតវិស័យ។

១៩. ការអនុម័តយល់ព្រមលើការវិនិយោគមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យគឺត្រូវ៖

ក. រាល់ការវិនិយោគមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យដែលមានចំនួនតិចជាង ឬស្មើ ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក អាចអនុម័តដោយគណៈកម្មការដែលមានសមាសភាពដូចខាងក្រោម។

នាយកគម្រោងក៏អាចស្នើជំនាញការ ឬអ្នកឯកទេសឲ្យមានយោបល់តាមជំនាញរបស់ខ្លួនក្នុងករណីចាំបាច់ តែពួកគេមិនចូលរួមក្នុងការសំរេចចិត្តឡើយ។

- នាយកគម្រោង
- នាយករងគម្រោងទទួលបន្ទុកការិយាល័យភូមិភាគពាក់ព័ន្ធ
- ប្រធានគ្រប់គ្រងគម្រោងផ្នែកខ្សែសង្វាក់តម្លៃ
- ប្រធានគ្រប់គ្រងគម្រោងផ្នែកប្រតិបត្តិការ
- ជនបង្គោលទទួលបន្ទុកខ្សែសង្វាក់តម្លៃគោលដៅ
- ប្រធានគ្រប់គ្រងការិយាល័យមណ្ឌលភូមិភាគពាក់ព័ន្ធ
- ជំនាញការខ្សែចង្វាក់តម្លៃ
- មន្ត្រីលទ្ធកម្ម
- មន្ត្រីហិរញ្ញវត្ថុ

ខ. រាល់ការវិនិយោគមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យដែលមានចំនួនលើសពី ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក តម្រូវឱ្យមានការអនុម័តពីសមាជិកក្រសួងពាណិជ្ជកម្ម នៃគណៈកម្មការត្រួតពិនិត្យលទ្ធកម្ម (PRC) តាមកម្រិតជាក់ស្តែង អាស្រ័យលើទំហំនៃការវិនិយោគ[2]។

គ. រាល់ការវិនិយោគមូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យដែលមានចំនួនលើសពី ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកដែលមិនបានកំណត់នៅក្នុងផែនការសកម្មភាពដែលបានព្រមព្រៀងគ្នាចេញពីវេទិកាសម្របសម្រួលពហុភាគីពាក់ព័ន្ធ (MSP) ត្រូវតែបញ្ជូនទៅមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) ដើម្បីទទួលបាន "ការមិនជំទាស់" ជាមុនសិន។ ការអនុម័តរបស់មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម គឺជាតម្រូវការចាំបាច់ចាប់តាំងពីដំណាក់កាលរៀបចំឯកសារទស្សនទានសម្រាប់ការវិនិយោគ ដែលរួមទាំងគោលបំណង និងហេតុផល ថវិកាប៉ាន់ស្មាន និងដៃគូអនុវត្តន៍ដែលបានស្នើសុំ។

## ២.៥. ការដាក់សំណើសុំថវិកា

២០. សំណើសុំថវិកាសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត តាមរយៈមូលនិធិសម្របសម្រួលការអភិវឌ្ឍតាមវិស័យ ត្រូវភ្ជាប់ជាមួយនូវៈ

[2] គណៈកម្មការត្រួតពិនិត្យលទ្ធកម្ម (PRC) កម្រិតធំទទួលបន្ទុកអនុម័តលើថវិកាវិនិយោគមានតម្លៃលើសពី ១លានដុល្លារ។ គណៈកម្មការត្រួតពិនិត្យលទ្ធកម្មកម្រិតមធ្យម អាចអនុម័តលើថវិកាវិនិយោគមានតម្លៃពី ៥០.០០០ ដល់ ១លានដុល្លារ ហើយគណៈកម្មការត្រួតពិនិត្យលទ្ធកម្មកម្រិតតូច អនុម័តលើថវិកាវិនិយោគរហូតដល់ ៥០.០០០ ដុល្លារ។

- ការវិភាគស្ថានភាព
- ទស្សនៈទាន និងគំនិតសំខាន់ៗដូចបានឯកភាពនៅក្នុងផែនការខ្សែចង្វាក់តម្លៃ
- កម្មវត្ថុនិងបរិយាយពីការវិនិយោគ
- ផែនការប្រតិបត្តិការ និងថែទាំ
- ថវិកាប៉ាន់ស្មាន
- ផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដូចជាៈ ១)លទ្ធផលទទួលបាន ២) ចំណាយជាមធ្យមសម្រាប់ម្នាក់ៗ ៣) ប្រាក់ចំណេញ និង ៤) ផលប្រយោជន៍សម្រាប់គ្រួសារក្រីក្រដែលអាចវាស់វែងបាន
- ផែនការ និងវិធីសាស្រ្តលទ្ធកម្ម
- ផែនការចំណាយ
- ការគ្រប់គ្រងមូលនិធិសម្របសម្រួលការអភិវឌ្ឍតាមវិស័យ

## ២.៦. ការវាយតម្លៃលើសំណើ

២១. ការវាយតម្លៃត្រូវបានធ្វើឡើងដើម្បីធានាបានចំណុចខាងក្រោមៈ

- ការវិនិយោគ និងសកម្មភាពដែលបានស្នើសុំ មានភាពត្រឹមត្រូវ ស្របតាមតម្រូវការ និងមានលក្ខណៈប្រទាក់ក្រឡាគ្នា និងផ្សារភ្ជាប់យ៉ាងច្បាស់លាស់ទៅនឹងផែនការសកម្មភាពនៃខ្សែសង្វាក់តម្លៃ។ លើសពីនោះ ការវិនិយោគពិតជាឆ្លើយតបទៅនឹងបញ្ហារាំងស្ទះក្នុងខ្សែសង្វាក់តម្លៃ។
- តាមការពិនិត្យផ្នែកបច្ចេកទេស ឃើញថាការវិនិយោគនេះនឹងអាចធ្វើទៅបាន។
- ការវិនិយោគ (ជាពិសេសហេដ្ឋារចនាសម្ព័ន្ធ) មានសក្តានុពលក្នុងការបង្កើតផលប៉ះពាល់ជាវិជ្ជមាន និងអាចធានាបាននិរន្តរភាព ក្រោមរូបភាពជាសាធារណៈ ឯកជន ឬតាមម៉ូឌែលជាសាធារណៈ និងឯកជន។
- ប្រសិនបើមានគោលដៅសេដ្ឋកិច្ច ផលចំណេញសេដ្ឋកិច្ចរបស់ផលិតផលចុងក្រោយ សេវា ឬបច្ចេកវិទ្យាដែលយកទៅប្រើប្រាស់ គួរតែរំពឹងទុកឱ្យហើយ។
- ការវិនិយោគដែលបានស្នើសុំនេះមានភាពត្រឹមត្រូវដោយពិចារណាពីចំណាយ និងអត្ថប្រយោជន៍ដល់តួអង្គខ្សែសង្វាក់តម្លៃ និងអ្នកទទួលផលរបស់គម្រោង (ដោយផ្ទាល់ ឬដោយប្រយោល)។
- អ្នកស្នើសុំមានភ័ស្តុតាងគ្រប់គ្រាន់ (បទពិសោធន៍ សុចរិតភាព សមត្ថភាព និងសមត្ថភាពគ្រប់គ្រង) ដើម្បីអនុវត្តគម្រោងវិនិយោគ និងការចាត់ចែងប្រតិបត្តិការតទៅទៀតប្រកបដោយនិរន្តភាព ហើយ

កំពុងកសាងសមត្ថភាពគ្រប់គ្រងបន្ថែម សមត្ថភាពហិរញ្ញវត្ថុ បច្ចេកទេស ឬស្ថាប័នដែលជាផ្នែកមួយនៃសំណើ។

- កត្តាសង្វាក់ផលិតកម្ម៖ ចំនួនទឹកប្រាក់វិនិយោគ (ដោយអ្នកដាក់ពាក្យសុំ តួអង្គខ្សែសង្វាក់តម្លៃដទៃទៀត និងដោយស្ថាប័នផ្សេងទៀត) អាចបង្កើនបានជាបន្តបន្ទាប់ ក្រោយពីបានទទួលថវិកាជំនួយឥតសំណង។
- ប្រសិនបើសំណើថវិកាជំនួយឥតសំណងនេះទាក់ទងនឹងការបង្កើត ឬការកែលម្អកន្លែង ឬសេវាដែលត្រូវបានរំពឹងថានឹងបន្តប្រតិបត្តិការបន្ទាប់ពីគម្រោងនេះបានបញ្ចប់ ផែនការហិរញ្ញវត្ថុ និងផែនការប្រតិបត្តិការត្រូវបង្កើតជាផ្នែកមួយនៃសំណើផ្តល់ហិរញ្ញប្បទាន។

## ២.៧. ការផ្តល់មូលនិធិ

២២. ក្នុងករណីដែលដៃគូអនុវត្តមូលនិធិសម្របសម្រួលការអភិវឌ្ឍតាមវិស័យ ត្រូវបានចាត់តាំងជាអ្នកគ្រប់គ្រងការវិនិយោគ នោះថវិកាមូលនិធិនេះនឹងត្រូវបានបង្វែរចេញពីគម្រោង ស្របតាមកាលវិភាគអនុវត្ត និងវិនិយោគដែលបានព្រមព្រៀងគ្នារវាងគម្រោង និងអ្នកទទួលឥណទានឥតសំណង ដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងឥណទានឥតសំណង។

២៣. មូលនិធិនេះនឹងត្រូវបានផ្ទេរទៅកាន់គណនីធនាគាររបស់អ្នកទទួល។

២៤. ការចាត់ចែងដែលបានបង្ហាញខាងក្រោមនេះ អាចយកទៅអនុវត្តដើម្បីទូទាត់ប្រាក់ទៅកាន់អ្នកទទួល៖

- ដំណាក់កាលទី១ (មូលនិធិចាប់ផ្តើម)៖ រហូតដល់ ៣០% នៃតម្លៃឥណទានឥតសំណងសរុបនឹងត្រូវបានប្រគល់បន្ទាប់ពីកិច្ចព្រមព្រៀងឥណទានឥតសំណងត្រូវបានចុះហត្ថលេខា ហើយវិភាគទានដៃគូត្រូវបានប្រមូល និងដាក់នៅក្នុងធនាគារ។
- ការទូទាត់បន្តបន្ទាប់ (រហូតដល់ ៥០%)៖ នឹងត្រូវប្រគល់ដោយផ្អែកលើសមិទ្ធផលនៃការអនុវត្តតាមដំណាក់ៗ និងការចំណាយថវិកាដំណាក់កាលមុន បន្ទាប់ពីបានដាក់ជូនរបាយការណ៍វឌ្ឍនភាពបណ្តោះអាសន្ននៃអនុគម្រោង។
- ដំណាក់កាលចុងក្រោយ (សមតុល្យដែលនៅសេសសល់)៖ បន្ទាប់ពីការដាក់ជូនរបាយការណ៍បញ្ចប់អនុគម្រោងដែលបញ្ជាក់ថាទទួលយកបាន។

២៥. របាយការណ៍បញ្ចប់គម្រោងគួររួមបញ្ចូលទាំង៖

- សមិទ្ធផលអនុគម្រោងដែលបានបញ្ជាក់នៅក្នុងសំណើ/កិច្ចព្រមព្រៀង
- របាយការណ៍ស្តីពីការប្រើប្រាស់ និងស្ថានភាពនៃមូលនិធិ នៅត្រឹមកាលបរិច្ឆេទរាយការណ៍
- របាយការណ៍សវនកម្មសាធារណៈ (បើមានការចាំបាច់)

# ៣. ការគ្រប់គ្រងវិនិយោគមូលនិធិសម្របសម្រួលការអភិវឌ្ឍតាមវិស័យ

## ៣.១. ជំនួយផ្នែកបច្ចេកទេសសម្រាប់ការបង្កើត និងអនុវត្តសំណើ

២៦. ក្រុមខ្សែសង្វាក់តម្លៃនឹងសម្របសម្រួលការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការបង្កើតសំណើសម្រាប់មូលនិធិសម្របសម្រួលការអភិវឌ្ឍតាមវិស័យដោយសហការជាមួយអ្នកជំនាញក្នុងការិយាល័យគ្រប់គ្រងគម្រោង។

## ៣.២. លទ្ធកម្ម

២៧. លើកលែងចំពោះការវិនិយោគលើមូលនិធីដែលត្រូវបានគ្រប់គ្រងឡើង ដោយការិយាល័យគ្រប់គ្រងគម្រោងផ្ទាល់ ដែលត្រូវអនុវត្តតាមនីតិវិធីរួមរបស់រដ្ឋាភិបាល និងគោលការណ៍ណែនាំស្តីពីលទ្ធកម្មនៃមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម រាល់ការអនុវត្តលទ្ធកម្មដែលចាំបាច់ក្រោមការវិនិយោគ ជាការទទួលខុសត្រូវរបស់អ្នកទទួលឥណទានឥតសំណង និងអនុវត្តទៅតាមនីតិវិធីកំណត់នៅក្នុងសំណើដែលបានអនុម័តរួច។ អ្នកទទួលឥណទានឥតសំណង នឹងធ្វើតាមដំណើរការដែលបានបញ្ជាក់ និងទទួលខុសត្រូវតែឯកឯងចំពោះការសម្រេចចិត្តចុងក្រោយ ចំពោះការជ្រើសរើសអ្នកផ្គត់ផ្គង់។

## ៣.៣. គណនេយ្យភាពក្នុងករណីការគ្រប់គ្រងជាបន្ទុករបស់ដៃគូអនុវត្តមូលនិធិសម្របសម្រួលការអភិវឌ្ឍតាមវិស័យ

២៨. អ្នកទទួលឥណទានឥតសំណងគួរតែរក្សាទុករាល់វិក្កយបត្រ បង្កាន់ដៃទទួលប្រាក់ តារាងតម្លៃ កិច្ចសន្យា កំណត់ហេតុកិច្ចប្រជុំ និងឯកសារផ្សេងទៀតដែលទាក់ទងនឹងការវិនិយោគដែលបានអនុម័តរួច។

២៩. អាជ្ញាធរមានសមត្ថកិច្ចចេញពីមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម និងរាជរដ្ឋាភិបាលកម្ពុជា រួមមានការិយាល័យគ្រប់គ្រងគម្រោង ឬតំណាងរបស់ខ្លួនអាចផ្ទៀងផ្ទាត់ឯកសារទាំងនោះនៅពេលណាមួយក៏បាន។

## ៣.៤. ការរៀបចំចាត់ចែងជួសជុល និងថែទាំ

៣០. ការទទួលខុសត្រូវចំពោះការជួសជុល និងថែទាំការិយាល័យដែលត្រូវបានបង្កើតឡើងក្រោមការគាំទ្រពីគម្រោងជាបន្ទុករបស់អ្នកទទួលឥណទានឥតសំណង។ គម្រោងជំរុញទីផ្សារសម្រាប់កសិករខ្នាតតូចនឹងមិនផ្តល់មូលនិធិបន្ថែមសម្រាប់គោលបំណងនេះទេ។

៣១. អ្នកទទួលឥណទានឥតសំណងគួរធានាថា ការរៀបចំផ្នែកហិរញ្ញវត្ថុឲ្យមានគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ និងថែទាំការិយាល័យណាមួយដែលបានបង្កើតឡើង ឬធ្វើឱ្យប្រសើរឡើងក្រោមឥណទានឥតសំណងរបស់មូលនិធិសម្រាប់ការអភិវឌ្ឍតាមវិស័យ។ អត្ថិភាពនៃការរៀបចំឲ្យមានការពេញចិត្តជាកត្តាចាំបាច់សម្រាប់ការទូទាត់សមតុល្យចុងក្រោយក្រោមឥណទានឥតសំណងនេះ។

**ក្រសួងពាណិជ្ជកម្ម**

គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (AIMS)

អង្គភាពគ្រប់គ្រងគម្រោង (PMO)

អ៊ីម៉ែល៖ cambodia.aims@gmail.com

www.moc.gov.kh/aims | facebook/cambodia.aims.project